# សុន្ទរកថា

## សម្តេចក្រឡាហោម ស ខេង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

### ក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

### ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥

សាលប្រជុំក្រសួងមហាផ្ទៃ (អាគារ S)

- **ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
- **ឯកឧត្តមប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីសមាជិក សមាជិកាអង្គសិក្ខាសាលា**

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានមកចូលរួមក្នុងពិធីបើក**សិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** ជាមួយឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់នាពេលនេះ។ ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមវាយតម្លៃខ្ពស់ និងសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមសិក្ខាសាលាដ៏មានសារៈសំខាន់នាថ្ងៃនេះ។

ខ្ញុំចាត់ទុកថា សិក្ខាសាលានាថ្ងៃនេះ គឺជាព្រឹត្តិការណ៍ដ៏មានអត្ថន័យបំផុតក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្រៅពីគោលបំណងផ្សព្វផ្សាយនូវខ្លឹមសារនៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន សិក្ខាសាលានេះក៏ជាសក្ខីភាពដែលឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាលក្នុងការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កិតការធ្វើសេចក្តីសម្រេចចិត្ត និងយន្តការផ្តល់សេវាឱ្យទៅកៀកជិតប្រជាពលរដ្ឋ សំដៅធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋយ៉ាង